**ឯកឧត្តម** Hidehisa HORINOUCHI **ឯកអគ្គរាជទូតនៃប្រទេសជប៉ុន ឯកឧត្តម យក់ ប៊ុយ រដ្ឋលេខាធិការនៃក្រសួងអប់រំយុវជននិងកីឡា និងជាតំណាងឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តម លោកជំទាវ អស់លោកលោកស្រីជាទីគោរព** !

ថ្ងៃនេះជាកិត្តិយសដ៏ឧត្តុង្គឧត្តមសម្រាប់រូបខ្ញុំនិងសហការីខ្ញុំ ដែលបានទទួលប័ណ្ណសរសើរពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុនប្រចាំឆ្នាំ២០១៧ ។ តម្លៃកិត្តិយសនេះ បានធ្វើឲ្យខ្ញុំនឹកដល់អនុស្សាវរីយ៍ល្អៗជាច្រើនក្នុងដំណើរជីវិតរបស់ខ្ញុំឡើងវិញ ក្នុងនោះមានជាអាទិ៍ ការប្រឡងជាប់ទទួលអាហារូបករណ៍របស់រាជរដ្ឋាភិបាលជប៉ុនដែលបានជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ឱកាសមាសមួយឲ្យខ្ញុំបានទៅបន្តការសិក្សានៅប្រទេសជប៉ុន។ បទពិសោធន៍ធ្វើដំណើររបស់ខ្ញុំទៅប្រទេសជប៉ុនលើកដំបូង និងក្នុងនាមជានិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យណាហ្គូយ៉ា កាលពី១៨ឆ្នាំកន្លងទៅគឺជាដំណើរជីវិតគួរឲ្យស្ញប់ស្ញែងសម្រាប់រូបខ្ញុំ ក្នុងនោះមិនត្រឹមតែធ្វើឲ្យខ្ញុំឈ្វេងយល់អំពីពិភពលោកថ្មីដែលខ្ញុំមិនដែលស្គាល់ទាល់តែសោះពីមុនមក ថែមទាំងដក់ជាប់ក្នុងចិត្ត និងបានធ្វើឲ្យមានផ្លាស់ប្តូរទស្សនៈ និងជីវិតរបស់ខ្ញុំថែមទៀត។

ខ្ញុំតែងតែទទួលបានការផ្តល់កិត្តិយស និងឱកាសធ្វើការជាមួយមិត្តភក្តិ និងដៃគូអភិវឌ្ឍន៍ភាគីជប៉ុននៅក្នុងជីវភាពការងារសំខាន់ៗ របស់ខ្ញុំនៅប្រទេសកម្ពុជា ចាប់តាំងពីខ្ញុំបានវិលមកមាតុប្រទេសវិញ ។ ក្នុងខណៈដែលខ្ញុំបានបំរើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៃប្រទេសកម្ពុជារបស់ខ្ញុំ និងស្របក្នុងខណៈដែលមានការផ្តល់ឱកាសពីថ្នាក់ដឹកនាំក្រសួង ពីឯកឧត្តមសាកលវិទ្យាធិការ ខ្ញុំបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការជួយកសាងរៀបចំបង្កើត និងបានបន្តការចូលរួមជាបន្តបន្ទាប់ជាមួយមជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំច្បាប់ជប៉ុននៅសាកលវិទ្យាល័យ RULE (Research and Education Center for Japanese Law) គឺនៅពេលដែលខ្ញុំជាសាស្ត្រាចារ្យច្បាប់ និងជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យរដ្ឋបាលសាធារណៈ ហើយនិងបានបន្តការខិតខំយ៉ាងសកម្មនូវការកសាងកម្មវិធីសហប្រតិបត្តិការថ្មីៗបន្ថែមទៀតរវាងសាកលវិទ្យាល័យដែលខ្ញុំបាននិងកំពុងបម្រើការសព្វថ្ងៃ(សាកលវិទ្យាល័យជាតិគ្រប់គ្រង) ជាមួយដៃគូអភិវឌ្ឍន៍សាកលវិទ្យាល័យ អង្គការ និងក្រុមហ៊ុនជប៉ុនមួយចំនួន ដែលទាំងអស់នេះ ជាលទ្ធផលនៃបទពិសោធន៍របស់ខ្ញុំទទួលបានកាលពីខ្ញុំនៅរៀនក្នុងប្រទេសជប៉ុន និងការជួយគាំពារលើកទឹកចិត្តពីឯកឧត្តមរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលកម្ពុជារបស់ខ្ញុំ។

ប័ណ្ណសរសើររបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ប្រគល់ជូនរូបខ្ញុំពេលនេះ គឺជាការបង្ហាញនូវគុណតម្លៃនៃសារៈសំខាន់នៃកិច្ចការសហប្រតិបត្តិការដែលខ្ញុំបានបំពេញដោយស្មោះស្ម័គ្រចាប់តាំងពីបានវិលមកមាតុប្រទេសវិញ។ កិច្ចសហប្រតិបត្តិការទាំងនេះសុទ្ធតែជាកិច្ចការដ៏ត្រឹមត្រូវបំរើឱ្យផលប្រយោជន៍នៃសង្គមទាំងពីរយ៉ាងល្អប្រសើ។ ឯកឧត្តមឯកអគ្គរាជទូតក៏បានរំលឹកដល់កិច្ចការដែលខ្ញុំសម្រេចបាន ទោះជារូបភាពណាក៏ដោយ ហើយទទួលបាននូវការទទួលស្គាល់ជាផ្លូវការ។ ដោយមានការលើកទឹកចិត្ត និងការគាំទ្រពេញទំហឹងពីសំណាក់ឯកឧត្តម ខ្ញុំនឹងបន្តបេសកម្មរបស់ខ្ញុំតទៅទៀត។

ខ្ញុំពិតជាមានក្តីរំភើបយ៉ាងខ្លាំងដែលរដ្ឋាភិបាលនិងប្រជាជនជប៉ុន មានទស្សនៈដ៏ឧត្តុង្គឧត្តមចំពោះស្នាដៃទំនាក់ទំនងល្អរបស់ខ្ញុំ ហើយខ្ញុំសូមថ្លែងអំណរគុណឯកឧត្តម អស់លោកលោកស្រីទាំងអស់ ដែលបានលើកទឹកចិត្ត និងគាំទ្រដល់រូបខ្ញុំជាបន្តបន្ទាប់ជាពិសេសនិងចំពោះការចូលរួមវត្តមាននាពិធីនេះ គឺជាការផ្តល់កិត្តិយសដល់រូបខ្ញុំ និងគ្រួសារខ្ញុំនាថ្ងៃនេះ។